ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍

# បទបង្ហាញ
# របាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ ២០២២
# និងលើកទិសដៅការងារ ឆ្នាំ ២០២៣
# របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងអភិវឌ្ឍន៍ជនបទ

# មាតិកា

១. តួនាទី ភារកិច្ចរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍

២. គម្រោងថវិកាឆ្នាំ ២០២២ ( មាតិកាថវិកា ឆ្នាំ២០២២ )

៣. ផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ ២០២២ និងការអនុវត្តផែនការសកម្មភាព

៤. បញ្ហាប្រឈម

៥. សំណូមពរ

៦. សន្និដ្ឋាន វាយតម្លៃការអនុវត្តឆ្នាំ ២០២២

## ១. តួនាទី ភារកិច្ចរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍

-សិក្សាស្រាវជ្រាវក្រុមគោលដៅដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងរាលដាលមេរោគអេដស៍ និងស្វែងរកដំណោះស្រាយឱ្យបានសមស្របតាមក្រុមគោលដៅនីមួយៗ

-រៀបចំគម្រោង និងពង្រឹងសកម្មភាពបន្ត នៃកម្មវិធីអេដស៍ និង ស្វែងរកជំនួយពីគ្រប់ប្រភព ដើម្បីដំណើរការណ៍

-ចងក្រងឯកសារ និងផលិតឧបករណ៍សម្រាប់បណ្តុះបណ្តាល និងអប់រំបន្ត

-ផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពផ្សេងៗ ដល់សមាជិកគណៈកម្មការ និង ក្រុមការងារដែលជាជំនួយឱ្យគណៈកម្មការ និងក្រុមគោលដៅ

-ផ្តល់ការប្រឹក្សាយោបល់ផ្សេងៗដល់ក្រុមប្រឈមមុខនឹងគ្រោះថ្នាក់ និងជនងាយរងគ្រោះ នៅតាម តំបន់ជនបទ

-ទំនាក់ទំនង និងសម្របសម្រួលជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បណ្តាក្រសួងពាក់ព័ន្ធនិងអង្គការនានា ក្នុងការស្វែងរកកិច្ចសហការនិងការគាំទ្រដល់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ នៃក្រសួងអភិវឌ្ឍន៍ជនបទ

-ជំរុញ និងបង្កើតឱ្យមានបណ្តាញនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទខេត្តនីមួយៗ ដើម្បីផ្សព្វផ្សាយ និងអប់រំផ្ទាល់ដល់សហគមន៍ អំពីការទប់ស្កាត់ និងបង្ការការរីករាលដាលមេរោគ ជំងឺអេដស៍

-តាមដាន និងវាយតំលៃលទ្ធផលការងារ ។

# ២. គម្រោងថវិកា ឆ្នាំ ២០២២ ( មាតិកាថវិកា ឆ្នាំ ២០២២)

| កម្មវិធី-អនុកម្មវិធី | ចំណាយចរន្ត | | |
|---|---|---|---|
| **កម្មវិធីទី ២ ៖ ការអភិវឌ្ឍសុខភាពការកែលម្អលក្ខខណ្ឌរស់នៅជនបទ** | សរុប | ជំពូក៦០ | ជំពូក៦១ |
| **អនុកម្មវិធីទី ៤ ៖** ការអភិវឌ្ឍអនាម័យជនបទ | 23.00 | 0.50 | 22.50 |
| **ចង្កោមសកម្មភាពទី ៥ ៖** ការងារអប់រំជំងឺឆ្លង និងសុខភាពផ្លូវភេទ | | | |
| **សកម្មភាពទី១ ៖** បើកវគ្គសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី លើកកម្ពស់ការយល់ដឹងពីជំងឺអេដស៍ កាមរោគ សុខភាពបន្តពូជ និងគ្រឿងញៀនដល់ប្រជាពលរដ្ឋសហគមន៍ជនបទ | 13.50 | 0 | 13.50 |
| **សកម្មភាពទី ២ ៖** ចុះត្រួតពិនិត្យ និងតាមដានការងារ | 9.0 | 0 | 9.0 |
| សរុប | 23.00 | 0.50 | 22.50 |

# ៣. ផែនការសកម្មភាពសម្រាប់អនុវត្ត ឆ្នាំ ២០២២ និងការអនុវត្តផែនការសកម្មភាព

| ឈ្មោះ អនុកម្មវិធី /ចង្កោមសកម្មភាព | %ចំណាយឥណទានចរន្ត | គោលដៅប្រចាំឆ្នាំ | ផែនការសកម្មភាព | ទីតាំងអនុវត្ត | លទ្ធផលក្នុងឆ្នាំ | % នៃគោលដៅសម្រេចបាន |
|---|---|---|---|---|---|---|
| **កម្មវិធីទី២ ៖ ការអភិវឌ្ឍសុខភាពការកែលម្អលក្ខខណ្ឌរស់នៅជនបទ** | | | | | | |
| **អនុកម្មវិធីទី ៤** ៖ ការអភិវឌ្ឍអនាម័យជនបទ | | | | | | |
| **ច.ស ទី ៥** ៖ ការងារអប់រំជំងឺឆ្លង និងសុខភាពផ្លូវភេទ | | | | | | |
| **សកម្មភាពទី១** ៖ បើកវគ្គសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពីលើកកម្ពស់ការយល់ដឹងពីជំងឺអេដស៍ កាមរោគ សុខភាពបន្តពូជ និងគ្រឿងញៀនដល់ប្រជាពលរដ្ឋសហគមន៍ជនបទ | 100.0% | ០១ វគ្គ | បើកវគ្គសិក្ខាសាលាផ្សព្វផ្សាយ | ខេត្តបាត់ដំបង | ០១ វគ្គ | 100.0% |
| **សកម្មភាពទី២** ៖ ចុះត្រួតពិនិត្យ និងតាមដានការងារ | 96.6% | ០៤ខេត្ត | ចុះត្រួតពិនិត្យ និងតាមដានការងារ | ខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តកំពង់ស្ពឺ | ០៣ ខេត្ត | 75.0% |

# ៤. បញ្ហាប្រឈម

- ថវិកាសម្រាប់អនុវត្តការងារនៅមានកម្រិតទាប

- បញ្ហា កូវីដ-19 ក្រសួងហិរវត្ថុកាត់កញ្ចប់ថវិកាសម្រាប់អនុវត្តន៍ការងារ

- ខ្វះការសហការរវាងគម្រោងឬដៃគូអភិវឌ្ឍន៍នានាជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ។

## ៥. សំណូមពរ

- បង្កើនកញ្ចប់ថវិកាជាតិសម្រាប់អនុវត្តការងារអេដស៍
- មានកិច្ចសហការ និងគាំទ្រធនធានថវិការវាងគម្រោងឬដៃគូអភិវឌ្ឍន៍នានារបស់ក្រសួង
- បង្កើនការគាំទ្រពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់

## ៦. សន្និដ្ឋាន វាយតម្លៃការអនុវត្តឆ្នាំ ២០២២

នៅក្នុង ២០២២ នេះ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងអភិវឌ្ឍន៍ជនបទ នឹងប្តេជ្ញាចិត្តខិតខំអនុវត្តនូវតួនាទី របស់ខ្លួនក្នុងការអនុវត្តសកម្មភាពការងារទៅតាមផែនការថវិកា និងផែនការយុទ្ធសាស្ត្រ ដើម្បីទទួលបាននូវលទ្ធផលគួរជាទីមោទនៈក្នុងការលើកកម្ពស់ និងផ្តោតកម្មវិធីអប់រំផ្សព្វផ្សាយ ចំពោះប្រជាពលរដ្ឋដែលមានសក្តានុពលប្រឈមមុខខ្ពស់ទៅនឹងគ្រោះថ្នាក់ នៃការចម្លងមេរោគអេដស៏ ជំងឺអេដស៍ និងសុខភាពផ្លូវភេទ ជាពិសេសយុវវ័យដែលត្រៀមនឹងធ្វើចំណាកស្រុក ក្រុមបុរសរួមភេទជា មួយបុរស និងក្រុមអ្នកប្រើគ្រឿងញៀន ទាំងនេះជាផ្នែកមួយ នៃការចូលរួមចំណែកក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្នុងការរួមចំណែកសម្រេចទស្សនវិស័យគោលដៅយុទ្ធសាស្ត្រជាតិ ៩៥ ៩៥ ៩៥ នៅ ឆ្នាំ២០២៥ ៖ ១). គ្មានការចម្លងមេរោគអេដស៍ថ្មី ២). គ្មានការរើសអើងលើអ្នកផ្ទុកមេរោគអេដស៍ ៣). និងគ្មានការស្លាប់ដោយសារជម្ងឺអេដស៍ សំដៅចូលរួមចំណែកជា មួយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សុខភាពផ្លូវភេទរបស់ប្រជាពលរដ្ឋតាមរយៈវិស័យអភិវឌ្ឍន៍ជនបទ ៕

# សកម្មភាពអនុវត្តន៍ការងាររបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍









# គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍



# សូមអរគុណ!